ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តក្រចេះ

# សារលិខិតអបអរសាទរ

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**
**នៃព្រះរាជាណាចក្រកម្ពុជា**

*ជាទីគោរពដ៏ខ្ពង់ខ្ពស់*

ថ្ងៃនេះជាប្រវត្តិសាស្ត្រថ្មីមួយទៀតសម្រាប់ព្រះរាជាណាចក្រកម្ពុជា ទទួលបានដំណាក់ប្រេងលើកដំបូងជាផ្លូវការ ដែលជានិមិត្តរូបនៃភាពជោគជ័យដ៏ត្រចះត្រចង់របស់ប្រជាជាតិទាំងមូល។

ក្នុងនាមក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តក្រចេះ សូមគោរពសម្តែងនូវការអបអរសាទរយ៉ាងក្លៀវក្លានិងស្មោះអស់ពីដួងចិត្តចំពោះសមិទ្ធផលថ្មីនេះ ដែលជាផ្លែផ្កានៃ**នយោបាយឈ្នះ ឈ្នះ** របស់**សម្តេចតេជោនាយករដ្ឋមន្ត្រី**។ ដំណាក់ប្រេងដំបូង គឺជាសក្ខីភាពនៃកិច្ចខិតខំប្រឹងប្រែង ព្យាយាម និងពុះពាររាល់ការលំបាកសព្វបែបយ៉ាងរបស់រាជរដ្ឋាភិបាល។

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមថ្លៃថ្លានេះ យើងខ្ញុំសូមសម្តែងនូវសេចក្តីគោរពដឹងគុណដ៏ស្មោះអស់ពីដួងចិត្តចំពោះគំរូវីរភាពដ៏ឆ្នើមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ** ដែលបានរួមចំណែកតស៊ូរំដោះប្រទេសជាតិស្វះស្វែងរកសន្តិភាព បង្រួបបង្រួមជាតិ កសាង និងអភិវឌ្ឍប្រទេសជាតិឲ្យមានការរីកចម្រើនដូចបច្ចុប្បន្ន។ រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ** បានធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាសម្រេចបាននូវសមិទ្ធផលដ៏ត្រចះត្រចង់ជាបន្តបន្ទាប់ ថែរក្សាបាននូវសុខសន្តិភាព អធិបតេយ្យភាព បូរណភាពទឹកដីដ៏រឹងមាំ ឯកភាពជាតិ ស្ថេរភាពជាតិ និងការរីកចម្រើនជឿនលឿនលើគ្រប់វិស័យ ព្រមទាំងទទួលបាននូវកិត្យានុភាពដ៏ស័ក្តិសម ទាំងក្នុងក្របខណ្ឌតំបន់ និងលើឆាកអន្តរជាតិ។

យើងខ្ញុំទាំងអស់គ្នា សូមប្រសិទ្ធពរជ័យសិរីសួស្តី ជ័យមង្គល វិបុលសុខបវរមហាប្រសើរថ្លៃថ្លាជូន **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវគារវកិច្ច និងស្មោះស្ម័គ្រដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ៕

ថ្ងៃ ៣ ០១កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០២០

**ប្រធានក្រុមការងាររាជរដ្ឋាភិបាល**
**ចុះមូលដ្ឋានខេត្តក្រចេះ**

**ព្រុំ សុខា**